សុន្ទរកថារបស់ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
០១ មីនា ២០១៧

- **សូមគោរព ឯកឧត្តម មួន វាសនា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា (CMAC)**
- **សូមគោរព លោក Shibata Mikio ប្រធានតំណាងអង្គការសកម្មភាពកម្ចាត់មីនជប៉ុន (JMAS)**
- **សូមគោរព លោកស្រី Matsuura Ayumi ប្រធានគម្រោងអង្គការ IVY**
- **សូមគោរព លោកវេជ្ជបណ្ឌិត នុត ស៊ីណាត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ**
- **សូមគោរព លោក Matsuoka Takuya  ប្រធានគម្រោងអង្គការWorld Vision Japan**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយ សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនចំនួន៣រួមមាន៖ "គម្រោងបង្កើនសមត្ថភាពក្រុមបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមសម្រាប់CMAC នៅឆ្នាំទី៣" ដែលផ្តល់ជូនដល់អង្គការJMAS "គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្មក្នុង២ខេត្ត នៅឆ្នាំទី២" ដែលផ្តល់ជូនដល់អង្គការIVY និង "គម្រោងលើកកម្ពស់សុខភាពមាតា និងទារកក្នុងខេត្តតាកែវ នៅឆ្នាំទី១" ដែលផ្តល់ជូនដល់អង្គការWorld Vision Japan ។

ជំនួយទី១ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៥៤០,000ដុល្លារអាមេរិក ដល់អង្គការJMAS។ អ្នកជំនាញរបស់អង្គការJMAS នឹងបន្តសកម្មភាពបណ្តុះបណ្តាលបន្ថែមទៀតនៅតំបន់ដែលនៅសល់កាកសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងគោលបំណងបង្កើនសមត្ថភាពបន្ថែមដល់ក្រុមអន្តរាគមន៍បោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម(ERWI)របស់CMAC និងពិនិត្យនូវលទ្ធភាពនៃការផ្ទេរជំនាញផ្នែកបច្ចេកទេសចុងក្រោយបំផុតដូចជា ការប្រើប្រាស់យន្តហោះdroneជាដើម។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រជាជនទាំងអស់ក្នុងតំបន់ នឹងរួចផុតពីការភ័យខ្លាចដោយសារកាកសំណល់ជាតិផ្ទុះពីសង្គ្រាមទាំងអស់នោះ ហើយគម្រោងនេះ នឹងរួមចំណែកក្នុងការកែលម្អបរិស្ថានដើម្បីអោយការរស់នៅរបស់ប្រជាជនអាចប្រព្រឹត្តទៅបានប្រកបដោយស្ថេរភាព និងអភិវឌ្ឍសហគមន៍របស់ពួកគេជាបន្តទៅទៀត។

ជំនួយទី២ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៣៨0,000ដុល្លារអាមេរិក ដល់អង្គការIVY។ មជ្ឈមណ្ឌលប្រមូលផ្តុំកសិផលស្វាយរៀងដែលត្រូវបានសាងសង់ក្នុងឆ្នាំទី១នៃគម្រោងនេះ បានក្លាយជាគំរូឈានមុខមួយ។ ដើម្បីលើកស្ទួយតម្លៃបន្ថែមប្រកបដោយនិរន្តភាព តាមរយៈសកម្មភាពគម្រោងនៅឆ្នាំទី២នេះ ខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌលនេះ នឹងដើរតួនាទីជាគំរូនាំមុខកាន់តែល្អប្រសើរសម្រាប់សហគមន៍កសិកម្មនៅក្នុងខេត្តស្វាយរៀង និង

ខេត្តដទៃទៀត។ នៅក្នុងខេត្តព្រះវិហារ ជាទំលាប់កសិករដាំដុះស្រូវដោយប្រើវិធីសាស្ត្រសរីរាង្គ។ គម្រោងនេះ ត្រូវបានរំពឹងថា ចំណូលរបស់កសិករទាំងអស់ នឹងមានលក្ខណៈប្រសើរឡើង តាមរយៈការបង្កើនសមត្ថភាពគ្រប់គ្រងរបស់សហគមន៍កសិករ និងសម្ព័ន្ធសហគមន៍កសិករ ដើម្បីពង្រឹងទីផ្សារ និងគុណភាពនៃអង្ករសរីរាង្គរបស់សហគមន៍អោយកាន់តែល្អប្រសើរ។

ជំនួយទី៣ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៤៦០,000ដុល្លារអាមេរិក ដល់អង្គការWorld Vision Japan។ គម្រោងនេះ នឹងត្រូវបានអនុវត្តក្នុងខេត្តតាកែវ ដោយសារតែអត្រាមរណភាពទារកនៅមានអត្រាខ្ពស់ ហើយជម្ងឺដែលឆ្លងតាមទឹកមិនស្អាត ក៏នៅមានអត្រាខ្ពស់ធៀបនឹងអត្រាទូទាំងប្រទេស។ តាមរយៈគម្រោងនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការថែទាំសុខភាពមាតានិងទារក នឹងត្រូវបានលើកកម្ពស់ ហើយការទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព ក៏នឹងត្រូវបានធានានៅក្នុងតំបន់គោលដៅនៃគម្រោងនេះផងដែរ។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅតាមកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថា គម្រោងទាំង៣ដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា។

**សូមអរគុណ!**